ព្រលឹងមានដែរឬទេ ?

ដកស្រង់ពីគម្ពីពុទ្ធសាសនាអនាមិក[1]មួយជាភាសាបាលីស្តីពីការពីការសារសងរវាង ព្រះចៅមីលិនដាបញ្ហានៅប្រទេសឥណ្ឌា ជាមួយនឹង ភិក្ខុនាគសេនា (ស្ថិតនៅប្រហែលនៅសតវត្សទី ១៦៣ ទៅ ៩៥ មុនគ.ស.)

- ពិក្ខុនាគសេនា មានព្រះពុទ្ធដីកាទៅកាន់ព្រះចៅ មីលិនដា ថា : មហារាជ្ស តើ Vedagu[2] (ព្រលឹង) មានដែរឬទេ ? ហើយអ្វីទៅជា ព្រលឹង ?
- ព្រះចៅ មីលិនដា ឆ្លើយតបថា : ព្រលឹង ដែលរស់នៅក្នុងខ្លួនយើង ដែលមើលឃើញរូប តាមរយៈភ្នែក ឮសម្លេង តាមរយៈត្រចៀក ស្គាល់ឃ្លិន តាមរយៈច្រមុះ ភ្លក្សរសជាតិ តាមរយៈអណ្តាត ពាល់វត្ថុជាក់ស្តែង តាមរយៈកាយ ស្គាល់ បាតុភូត តាមរយៈវេទនា ; តើនរណា - ដូចភិក្ខុ និង យើងដែល អង្គុយនៅក្នុងវិមាននេះ ហើយសម្លឹងមើលតាមបង្អួច ជ្រើសរើសទិស ខាងកើត ខាងលិច ខាងជើង ខាងត្បូង តាមចំណង់ចិត្ត - ហើយក៏អាចក្រឡេក តាមទ្វារ បានតាមចំណង់ចិត្តបានដែរ។
- មហារាជ្ស អាត្មាភាព នឹងផ្លែងថ្វាយអំពី ទ្វារ៥។ សូមព្រះអង្គសញ្ជឹងចិត្តស្តាប់អាត្មាភាព : ប្រសិនជាព្រលឹង មើល

---

[1] គម្ពីនេះ បានបកប្រែបែបបើយ៉ាងជាភាសាចិនប្រហែលនៅសតវត្សទី ៣១៧ ទៅ ៤២០ ក.ស.គ. មានចំណងជើងថា « សៀវភៅ នៃភិក្ខុនាគសេនា »។ លោក Louis FINOT បកប្រែជាភាសាបារាំង ពី ភាសា បាលី ចុះផ្សាយពីអ្នកបោះពុម្ពផ្សាយ GUILLIMARD នៅឆ្នាំ១៩៩២។

[2] Devagu (ពាក្យ បាលី) : អ្នកដែលសំរេចបាន នូវការចេះដឹងខ្ពង់ខ្ពស់ បំផុត។ ទីនេះ យើង ប្រើពាក្យ ព្រលឹងមាននៅក្នុងខ្លួនមនុស្ស។

យើញរូប តាមរយៈភ្នែក - ដូចយើងទាំងឡាយនោះដែរ ដែលកំពុងអង្គុយក្នុងវិមាននេះ មើលឃើញរូប តាមបង្អួចណាមួយ ដែលយើងជ្រើសរើស - យើងអាចសន្និដ្ឋានបានថា ព្រលឹង ក៏នឹងអាច មើលឃើញរូប តាមរយៈ ត្រចៀក ច្រមុះ អណ្ដាត កាយ វេទនា ក៏អាចឮ សម្លេង តាមរយៈភ្នែក ច្រមុះ ។ល។ តើវាពិតជាដូច្នេះមែនឬ ?

- ព្រះចៅ មីលិនដា ឆ្លើយតបថា : មិនពិតនោះទេ ព្រះថេរៈ។
- ភិក្ខុ នាគសេនា បន្ដពុទ្ធដីកាថា : ដូច្នេះ ការអះអាងរបស់ព្រះអង្គ វាមិនត្រូវគ្នាទេ - ដូចថា : ប្រសិនបើបង្អួច នៃបន្ទប់ដែលយើងកំពុងអង្គុយនេះ វាបាក់រលំអស់, យើងប្រហែលជាអាច ក្រឡេកទៅខាងក្រៅ មើលឃើញស្រួល នូវរូបទាំងឡាយ នៅក្នុងទីវាលដ៏ធំទូលាយ។ តើព្រលឹង ដែលគ្មានភ្នែក វាអាចមើលឃើញស្រួលនៅក្នុងទីវាលធំទូលាយ នូវរូបទាំងឡាយបានដែរឬទេ ? ត្រចៀក ច្រមុះ អណ្ដាត រូបកាយ ត្រូវបានគេបិទជិត វាប្រហែលជាអាចឮ ហិតឃ្លិន ភ្លក្សរសជាតិ និង ពាល់វត្ថុជាក់ស្ដែងបានដែរឬទេ ? អ្វីផ្សេងទៀត ដូចថា : ប្រសិនបើ បុគ្គលឈ្មោះ ដីណា ដែលនៅទីនេះ ចេញពីបន្ទប់នេះ ហើយទៅឈរនៅត្រង់ខ្លោងទ្វារ, តើព្រះអង្គ ប្រហែលជាដឹងថាបុគ្គលនេះ ចេញពីខ្លោងទ្វារដែរឬទេ ? ហើយប្រសិនបើ បុគ្គលនេះ ចូលមកក្នុងបន្ទប់វិញ តើព្រះអង្គ ប្រហែលជាអាចដឹងបានដែរឬទេ ? ប្រសិនបើគេយក សារធាតុមួយ មានរសជាតិទៅ

ដាក់លើអណ្ដាត តើព្រលឹង រាប្រហែលជាអាចស្គាល់ នូវរស ជាតិ ល្វីង ប្រៃ ជូរចត់ ជូរផ្អែម បានដែរឬទេ ? អ្វីផ្សេង ទៀត ដូចថា : ឧបមាថា គេយកពាងស្រាត្នោតមួយរយ ហើយគេយកមនុស្សម្នាក់មកចង រួចដាក់វាក្នុងពាងស្រា ត្នោតមួយ, សួរថា តើព្រលឹង រាប្រហែលជាអាចដឹងដែរថា ស្រាត្នោតនៅក្នុងពាងនោះ រាមានរសជាតិផ្អែមឬទេ ? ចំពោះយើង គឺពិតជាព្រលឹង រាប្រហែលជាមិនអាចដឹង បាននោះឡើយ។

- ព្រះចៅ មីលិនដា ឆ្លើយជាសំនួរថា : ហេតុអ្វី ?
- ភិក្ខុ នាគសេនា មានព្រះពុទ្ធដីកាបន្ដថា : ពីព្រោះស្រា ត្នោត រាមិនហូរចូលទៅក្នុងមាត់ របស់ព្រលឹងបាននោះ ឡើយ។
- ព្រះចៅ មីលិនដា មានបន្ទូលថា : ភិក្ខុជាទីគោរព យើង មិនអាចពិភាក្សា ជាមួយអ្នកជំនាញខាងវិចារវិទ្ធដូចព្រះ អង្គបានទេ។ ដូច្នេះ សូមមេត្ដាព្រះថេរ: ជួយពន្យល់ដល់ យើងផង។

ព្រះថេរ: នាគសេនា ព្រះអង្គ ធ្វើការពន្យល់ទៅព្រះចៅ មីលិន ដា អំពីបញ្ហាអត្ថភាព នៃព្រលឹង ដោយយក អភិធម៌ (Abhidhamma[3]) ជាមូលដ្ឋាន ដែលមានសេចក្ដី ដូចតទៅ :

[3] L'Abhidhamma (បាលី, សំស្ក្រឹតអានថា : Abhidharma) — ជាសេចក្ដីអត្ថ ធិប្បាយអំពីទ្រឹស្ដីពិសេស ឬ នៅក្រៅពីពុទ្ធសិក្ខាបទ។ អភិធម្មនេះ ជា ផ្នែក នៃព្រះត្រៃបិតក ជាអត្ថបទ ទាក់ទងនឹង បទបង្ហាញ ខាងចិត្ត សាស្ត្រ និងទស្សនវិជ្ជា នៃឱវាទរបស់ព្រះពុទ្ធ។

ដូចជា លទ្ធផល កើតឡើងដោយការយល់ឃើញ ដែលមើលឃើញ ; និង ការ:ទាំងឡាយ នៃការយល់ដឹង ដែលអមដំណើរដោយ - ផុសនា, វេទនា, ការយល់, ចិត្ត, សមាធិក, ជីវិតនិជ្ជ័យ, មនសិការ ដែលជាលទ្ធផល ទៅតាមអ្វីដែលវាកើតពីមុនៗមក។ ដូច្នេះ វាគ្មាន ព្រលឹង ទេ។